ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
ចូល លេខ ១១១១ ថ្ងៃទី ២៤ ខែ ៣ ឆ្នាំ២០២៥ ម៉ោង ១២:០០ បញ្ជូន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខៈ ៤៧៦ សជណ.អស

ថ្ងៃ សុក្រ ៨ រោច ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**កម្មវត្ថុ៖** ករណីរបាយការណ៍ស្តីពីលទ្ធផលនៃការចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីឌីជីថលអាស៊ានលើកទី៥ នៅប្រទេសថៃ នៅថ្ងៃទី១៦-១៧ ខែមករា ឆ្នាំ២០២៥ និងសំណើគោរពសុំគោលការណ៍លើការងារបន្ត។

**យោង ៖** - លិខិតលេខ៤៣៩ បទ. ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៥ របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីជ្រាបថា រាជរដ្ឋាភិបាលបានឃើញរបាយការណ៍ស្តីពីលទ្ធផលនៃការចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីឌីជីថលអាស៊ានលើកទី៥ នៅប្រទេសថៃ នៅថ្ងៃទី១៦-១៧ ខែមករា ឆ្នាំ២០២៥ និងឯកភាពជាគោលការណ៍ជូនក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ទ.**) ដូចខាងក្រោម៖

១- **ក.ប.ទ.** ចូលរួមក្នុងកិច្ចប្រជុំកំពូលសកលស្តីពី បញ្ញាសិប្បនិម្មិត ឆ្នាំ២០២៥ (AI for Good Global Summit 2025) នៅថ្ងៃទី៨ ដល់ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៥ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។

២- **ក.ប.ទ.** រៀបចំវេទិកាជាតិស្តីពី បញ្ញាសិប្បនិម្មិត ត្រីមាសទី២ ឬទី៣ ឆ្នាំ២០២៥ ក្នុងគោលបំណងលើកកម្ពស់ការប្រើប្រាស់បញ្ញាសិប្បនិម្មិត ប្រកបដោយសុវត្ថិភាព សន្តិសុខ និងភាពទុកចិត្តសម្រាប់វិស័យសាធារណៈនិងឯកជន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ហ៊ុយ វណ្ណៈ**

**ចម្លងជូន៖**
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ឯកសារ កាលប្បវត្តិ